# បាឋកថា
# របស់សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ អនុប្រធានគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈចលនាមហាជន នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា

ក្រោមប្រធានបទ

# “ ដំណើរឆ្ពោះ ដើម្បីបុព្វហេតុជាតិ និងប្រជាជនកម្ពុជា”

ថ្ងៃអាទិត្យ ១៣រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៦

## ១. អំពីសាវតា

- មានស្រុកកំណើតនៅភូមិដូនមាស ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ ក្នុងគ្រួសារជាកូនកសិករ មានលោកឪពុកឈ្មោះ ម៉ែន យ៉ន និងអ្នកម្ដាយ ប្រាក់ សំអាត (លោកទាំងពីរបានត្រូវបាន ប៉ុល ពត សម្លាប់)។ ខ្ញុំគឺជាកូនច្បងគេ ក្នុងចំណោមបងប្អូនស្រី ៣នាក់ គឺ ម៉ែន សំអ៊ីន និង ម៉ែន សំអូន
- ស្វាមីគឺ **ឯកឧត្តមនាយឧត្តមសេនីយ៍ ប៉េង ប៉ាត់** សមាជិកព្រឹទ្ធសភា (មរណភាពឆ្នាំ២០១៦) មានកូនចំនួន ០២នាក់៖ ទី១ **ប៉េង ពោធិ៍សា** អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង និងទី២ **ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន
- ក្នុងវ័យកុមារភាពខ្ញុំនិងបងប្អូនស្រីពីរនាក់ទៀតរស់នៅជាមួយជីដូន និងចូលរៀននៅបឋមសិក្សាសំបូរ រហូតដល់ឆ្នាំ ១៩៦៧ ក៏បានរៀនសូត្រនៅខេត្តក្រចេះ ពេលនោះរៀនផង ជួយលក់នំជីដូនផង ។
- ក្នុងអំឡុងពេលវិស្សមកាល ខ្ញុំបានសុំការអនុញ្ញាតពីជីដូនជាច្រើនលើកច្រើនសារ ទើបគាត់សម្រេចចិត្តឲ្យខ្ញុំបានចាកចេញពីស្រុកកំណើតមកភ្នំពេញជាលើកដំបូងតែម្នាក់ឯង

ដើម្បីស្វែងរកប្រាក់ចំណូល និងដកស្រង់បទពិសោធន៍ជីវិត និងរៀនសូត្រផងដែរ។ ម្តាយធំរបស់ខ្ញុំមានកូនពីរនាក់ ត្រូវជាជីទូតមួយរបស់ខ្ញុំ។ ខ្ញុំបានមកធ្វើការនៅផ្ទះបងស្រីជីទូតមួយដែលជា អ្នកបម្រើការលើយន្តហោះ នៅម្តុំផ្សារស៊ីឡឹប។ ពេលនោះ ខ្ញុំធ្វើការជាមេផ្ទះរៀបចំអាហារ បោកគក់រៀបចំសម្លៀក បំពាក់ជូនគាត់ និងរៀនបន្ថែមខ្លួនឯងនៅពេលយប់។

- ក្រោយពីបាននៅជាមួយបងស្រីជីទូតមួយ មួយរយៈមក ខ្ញុំក៏បាន ត្រឡប់មកកាន់ស្រុកកំណើត ព្រោះសាលារៀនត្រូវចូល កងវិញ។
- សង្គ្រាមនៅកម្ពុជាក៏បានចាប់ផ្តើមកើតឡើងដោយមានរដ្ឋប្រហារទម្លាក់ **សម្តេចព្រះ នរោត្តម សីហនុ** នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០។ ខ្ញុំនៅចាំបានថា នៅវេលាម៉ោងប្រមាណ ៨កន្លះព្រឹក ក្នុងឆ្នាំ១៩៧០ ពេលដែលខ្ញុំកំពុងអង្គុយក្នុងថ្នាក់រៀនជាមួយមិត្តភក្តិដទៃទៀត បានឮសូរសំឡេងផ្ទុះជាច្រើនគ្រាប់ (ដែលជាសកម្មភាពរបស់ទាហានលន់ នល់) បានធ្វើឲ្យមានការផ្អើលឈូឆរទាំងគ្រូ និងសិស្ស ហើយពេលនោះ ក៏ត្រូវចំពេលដែលប្រជាពលរដ្ឋខ្មែរទូទាំង

ប្រទេសត្រៀមរៀបចំទទួលទេវតាឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។ នៅពេលនោះសាលាត្រូវបិទទ្វារទាំងស្រុងដោយសារសង្គ្រាម។

## ២. ស្ម័គ្រចិត្តចូលបម្រើកងទ័ព

- ក្នុងឆ្នាំ១៩៧០ ក្នុងវ័យអាយុ ១៧ឆ្នាំ ខ្ញុំក៏បានចាប់ផ្តើមជីវិតជាយុទ្ធនារីក្នុងអង្គភាពកងទ័ពរំដោះប្រចាំស្រុកសំបូរនៃខេត្តក្រចេះ គឺអង្គភាព ២០៣ ។ ការសម្រេចចិត្តចូលរួមក្នុងចលនាតស៊ូនាពេលនោះ គឺឆ្លើយតបនឹងការអំពាវនាវរបស់ **សម្តេចព្រះនរោត្តម សីហនុ** ឲ្យយុវជន យុវនារី សិស្ស និស្សិត និងគ្រូបង្រៀនចូលរួមក្នុងចលនាតស៊ូជាមួយកងទ័ពរំដោះដោយស្ម័គ្រចិត្ត។ ព្រោះពេលនោះអាមេរិកបានទម្លាក់គ្រាប់បែកបេ៥២ គ្រាប់បែកចង្កោមបាញ់រះមកលើប្រជាពលរដ្ឋស្លូតត្រង់ ក្មេង ចាស់ ប្រុស ស្រី រួមទាំងព្រះសង្ឃ អាចារ្យ បានរងរបួស និងស្លាប់ជាច្រើននាក់ ឆេះផ្ទះសម្បែង សាលារៀន វត្តអារាម ស្រែចម្ការរបស់ប្រជាជនជាច្រើនកន្លែងត្រូវរងការខូចខាតស្ទើរតែគ្មានសល់ ។
- ខ្ញុំចង់បញ្ជាក់ ៖ ពេលនោះយើងមានភារកិច្ច បំផុសចលនាអប់រំប្រជាជនឲ្យយល់ដឹង អំពើក្បត់ជាតិ ក្បត់ប្រជាជន ការចាប់ដៃជាមួយសត្រូវ ការជួយគាំទ្រទ័ពអាកាសរបស់អាមេរិកកាំងទម្លាក់គ្រាប់បែក មកលើប្រជាជនស្លូតត្រង់

ស្លាប់ និងរបួស ដាច់ដៃ ដាច់ជើង។ ក្រុមយើងក៏បាន បំផុសស្មារតីឈឺចាប់ផង ជួយព្យាបាលអ្នករបួសផង។ ពេលនោះហើយដែលពួកគាត់យល់ បានគាំទ្រយើង ស្រឡាញ់យើង ការពារយើង មានព័ត៌មានអ្វីក៏ពួកគាត់ បានរាយការណ៍ និងផ្តល់ដំណឹងឲ្យពួកយើងបានដឹងភ្លាមៗ អំពីសត្រូវ។ (យើងនៅកន្លែងណា គឺជីកលេណដ្ឋានកន្លែង នោះ)

## ៣. បេសកកម្មក្នុងអង្គភាព និងអត្ថហេតុ

- អង្គភាពតម្រូវឲ្យខ្ញុំចូលរៀនវគ្គនយោបាយ យោធា និង បន្តចូលរៀនលើមុខវិជ្ជាពេទ្យបន្ថែមទៀត។ *នៅពេលនោះ ខ្ញុំបានឆ្លងកាត់ការលំបាកយ៉ាងច្រើន ដោយត្រូវរៀនសូត្រ ផង អនុវត្តផ្ទាល់ផង ស្តាប់តាមបញ្ជារបស់វេជ្ជបណ្ឌិត និង ធ្វើការពិនិត្យ ព្យាបាលអ្នករងរបួសផង ហើយនៅពេលអង្គ ភាពផ្លាស់ប្តូរទីតាំងម្តងៗ ឬដឹកជញ្ជូនអ្នករបួសចេញពី មន្ទីរពេទ្យ គឺត្រូវចេញដំណើរនៅពេលយប់តែប៉ុណ្ណោះ ព្រោះថា យើងមិនអាចចល័តកម្លាំងដោយរថយន្តបានទេ ដោយសារតែត្រូវរក្សាការសម្ងាត់ ដើម្បីជានាសុវត្ថិភាព សម្រាប់អង្គភាពទាំងមូល។*

- នៅដើមឆ្នាំ១៩៧១ អង្គភាពក៏បានផ្លាស់ប្តូរទីតាំងពីស្រុកសំបូរ ខេត្តក្រចេះ មកស្នាក់នៅឃុំសាន់គ ស្រុកស្ទោង ខេត្តកំពង់ធំ ដើម្បីអនុវត្តផែនការវាយរំដោះខេត្តកំពង់ធំ។ នៅពេលនោះ អង្គភាពរបស់យើងខ្ញុំបានធ្វើការចល័តជាញឹកញាប់ ពេលខ្លះត្រូវបំបែកកម្លាំងបន្តិំខ្លួនរស់នៅជាមួយប្រជាជនចន្លោះពី ១ខែ ២ខែ ព្រោះខ្លាចបែកការណ៍។ ការចល័តទ័ពនោះ គឺមាននៅតំបន់សន្ទុកក្រៅ តាំងក្រសៅ ដាំប្រាំងក្រហម ត្បូងក្រពើ ភូមិថ្មី និងផ្នែកខាងជើងនៃស្រុកសណ្តាន់ជាដើម។
- នៅពេលមកដល់ភូមិសាស្ត្រខេត្តកំពង់ធំ ខ្ញុំបានជួបសមមិត្តនារី ៣នាក់ទៀតគឺ សមមិត្តនារី សាម៉េត សមមិត្ត សូភី និង សមមិត្ត សាយ ។ អង្គភាពក៏បានតម្រូវឲ្យបោះទីតាំងនៅក្នុងព្រៃ (គឺត្រូវកាប់ដើមឈើធ្វើសសរ និងក្រងស្លឹកសម្រាប់ធ្វើជាជំបូល ដីកលេណដ្ឋាន និងរក្សាការសម្ងាត់ទីតាំង។ល។)
- ក្នុងពេលបំពេញការងារជាគ្រូពេទ្យ និងមានពេលខ្លះត្រូវប្តូរមកជាអ្នកដឹកជញ្ជូនស្បៀង អង្ករ អំបិល ថ្នាំពេទ្យទៅកាន់សមរភូមិ ពេលត្រឡប់មកវិញត្រូវថែទាំ និងព្យាបាលអ្នករបួសមកពីសមរភូមិមុខ (ពេលនោះមានអ្នករបួសដាច់ដៃទាំងសងខាង គឺខ្ញុំត្រូវបញ្ចុកអាហារទៀត និងមានពេលខ្លះ

ត្រូវព្យាបាលមានមានជំងឺសរសៃប្រសាទទៀត) និងអ្នកខ្លះទៀតត្រូវបញ្ជូនបន្តទៅកាន់មន្ទីរពេទ្យ ស្ថិតក្នុងស្រុកចំការលើខេត្តកំពង់ចាម (ពេលនោះខេត្តជាតំបន់ដែលត្រួតត្រាដោយលន់ ណល់)។ ការដឹកជញ្ជូនអ្នករបួសនេះមានការលំបាកណាស់ ត្រូវធ្វើដំណើរដោយថ្មើរជើង ៤-៦នាក់សម្រាប់សែងអ្នកជំងឺ ផ្លាស់វេនគ្នា ឬដឹកតាមកង់ដែលជានារីទាំងអស់។ ប្រសិនបើអ្នកពលីវិញត្រូវរៀបចំទុកដាក់ និងជូនដំណឹងដល់ក្រុមគ្រួសារសព ដើម្បីបានមកទទួលសពយកទៅធ្វើបុណ្យតាមប្រពៃណី ហើយពេលខ្លះត្រូវដឹកសពជូនដល់ក្រុមគ្រួសារ។ ខ្ញុំនៅចាំច្បាស់ថា ដល់ពេលប្តូរ វេនសែងអ្នករបួសគឺវេនខ្ញុំ និងបងស្រី គីម ឡាង ដោយសារ តែអ្នករបួសជាមនុស្សប្រុសមានមាឌធំ ខ្ញុំចាំមិនភ្លេចនៅពេលដែលលើកអ្នកជំងឺដាក់លើអង្រឹង ខ្ញុំនិងបងស្រី គីម ឡាង បានដួលអុកគូទ ដែលធ្វើឲ្យអ្នករបួសបន្ថែម ការឈឺចាប់ម្តងទៀត។ មួយវិញទៀត សំឡេងស្រែកថ្ងូររបស់អ្នកដែលរបួសបានដក់ជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំរហូតមកដល់បច្ចុប្បន្ននេះ។ (ដោយសារតែវិន័យ គឺមិនអនុញ្ញាតឲ្យសម្រាកតាមផ្លូវទេ គឺត្រូវប្តូរវេនគ្នា និងត្រូវធ្វើយ៉ាងណាត្រូវ

រក្សាសុវត្ថិភាពតាមផ្លូវ ក្នុងការដឹកអ្នករបួសឲ្យឆាប់បានដល់ពេទ្យធំ)។

- ដោយមានតម្រូវការជាចាំបាច់ ប្រធានអង្គភាពបានចាត់តាំងឲ្យក្រុមនារីយកសំបុត្រទៅជូនដល់យុទ្ធមិត្តនៅត្រើយម្ខាងទៀត (ខ្ញុំមានគ្នា ៣នាក់ មានតែខ្ញុំទេជាអ្នកចេះហែលទឹក) ខ្ញុំក៏បានទទួលភារកិច្ចនេះ ពេលដែលកំពុងត្រៀមហែលទឹក គឺមានយន្តហោះអាមេរិកនៅពីលើតាមប្រមាញ់ថត ក្រែងមានទ័ពយើងឆ្លងកាត់ ហើយទឹកស្ទឹងសែនក៏ឡើងខ្ពស់ ហូរខ្លាំង មានភ្លៀង និងផ្គររន្ទះទៀត។ ពេលនោះខ្ញុំបានត្រៀមដើមចេក និងស្លឹកឈើ ដើម្បីបន្លំខ្លួន ខ្ញុំបានក្រឡេកមើលទៅមុខ (ក៏មានអភូតហេតុកើតឡើងលេចចេញតាចាស់ម្នាក់ពុកចង្កា ស ស្លៀកពាក់ស ជិះទូកយ៉ាងលឿនសំដៅមករកខ្ញុំ ហើយបានប្រាប់ថា ៖
  - ចៅ ចៅ កុំទៅមុខទៀតអី ប្រសិនបើទៅទៀតនឹងមានគ្រោះថ្នាក់ហើយ
  - ដោយមិនបានចាប់អារម្មណ៍នឹងសម្ដីគាត់ ខ្ញុំបានឆ្លើយតបទៅគាត់វិញថា ទេ! លោកតាចៅមានការងារសំខាន់ណាស់ ដាច់ខាតត្រូវតែយកសំបុត្រទៅឲ្យមិត្តនៅត្រើយម្ខាងទៀត។

- ពេលនោះ លោកតាក៏បាត់ស្រមោលតែម្ដង បន្ទាប់មកខ្ញុំក៏បានឮស្នូរសំឡេងផ្ទុះគ្រាប់យ៉ាងខ្លាំង ខ្ញុំក៏បានក្រឡេកមើលទៅត្រើយម្ខាង យន្តហោះអាមេរិកបានទម្លាក់គ្រាប់បែក បេ៥២ ចំកន្លែងដែលយុទ្ធមិត្តរងចាំទទួលសំបុត្រនោះតែម្ដង (មិនចាំថាមានប៉ុន្មាននាក់ទេដែលបានស្លាប់)។ ពេលនោះខ្ញុំក៏បានសន្លប់បាត់ស្មារតី ដោយសារតែសម្លេងគ្រាប់ផ្ទុះឮស្នូរខ្លាំងពេក និងបានធ្វើឲ្យខ្ញុំហូរឈាមតាមត្រចៀកខាងស្ដាំ និងស្ដាប់មិនឮអស់រយៈពេល ៣ខែ
- បន្ទាប់មកទៀត ដោយសារខ្ញុំធ្វើការធ្ងន់ ខ្ញុំក៏បានធ្លាក់ខ្លួនឈឺធ្ងន់ ក្អកធ្លាក់ឈាម និងមានជំងឺគ្រុនចាញ់ទៀត ពីមួយថ្ងៃទៅមួយថ្ងៃជំងឺរបស់ខ្ញុំកាន់តែធ្ងន់ទៅៗ ហើយក្រុមគ្រូពេទ្យក៏អស់លទ្ធភាព ទៀតពេលនោះខ្ញុំក៏បានសន្លប់បាត់ស្មារតី ហើយមិត្តក្នុងក្រុមគិតថា មិនអាចមានជីវិតរស់បាន ពួកគេក៏បានដាក់ខ្ញុំនៅក្នុងព្រៃនោះទៅ ដោយដាក់ក្នុងអង្រឹងគ្របមុង និងបាំងតង់ និងមានសរសេរនៅលើក្រដាសមួយផ្ទាំងថា **សមមិត្តនារី ម៉ែន សំអន** (ការសរសេរឈ្មោះនេះជាអត្តសញ្ញាណ ដើម្បីប្រាប់

អ្នកដែល ធ្វើដំណើរតាមពីក្រោយផ្លូវនេះបានដឹងថា អ្នកនេះឈ្មោះអី? នៅអង្គភាពណា? ដើម្បីបានឲ្យគ្រួសារយកទៅចាត់ចែងបន្តទៀត)។បន្ទាប់មកពួកគេក៏បានត្រៀមចេញដំណើរ ពេលនោះហើយ ក៏មានតាចាស់សក់សម្នាក់បានមកដាស់ខ្ញុំដោយសម្លេងល្វើយៗថា ចៅ ចៅ ក្រោកឡើងគេទៅមុខអស់ហើយ។ ពេលនោះខ្ញុំក៏បានដឹងខ្លួន ក៏បានប្រាប់លោកតាថា ចៅទៅមុខមិនរួចទេ ចៅគ្មានកម្លាំងទេ ។ លោកតានោះ ក៏ដកបាយពំនូតពីក្នុងថង់យាមចំនួន ៣ដុំតូចៗ មកឲ្យខ្ញុំហូប ហើយនិយាយថា ហូបទៅចៅនឹងមានកម្លាំងអាចបន្តដំណើរជាមួយគេបាន (ពេលនោះខ្ញុំវង្វេងវង្វាយ មិនដឹងថាជារឿងពិត ឬមិនពិតនោះទេ ហាក់បីដូចជាយល់សប្តិ៍)។ ខ្ញុំក៏ទទួលមកហូប ហើយលោកតានោះក៏មិនដឹងបាត់ទៅទីណា។ ពេលហូបហើយស្រាប់តែខ្ញុំក៏មានកម្លាំងបន្តិច និងបានរើបម្រាស់ខ្លួនក្នុងអង្រឹង ស្របពេលដែលបងស្រី គីម ឡាង មិនអស់ចិត្តក៏ងាកក្រោយដោយឃើញអង្រឹងរង្គើ គាត់បានគោះឈើជាសញ្ញាប្រាប់តៗគ្នា និងបានស្រែកថា «មិត្ត

រស់វិញហើយ មិត្តរស់វិញហើយ» គាត់បានស្ទុះត្រឡប់មករកខ្ញុំវិញយ៉ាងប្រញាប់ប្រញាល និងបានគ្រាខ្ញុំចុះពីលើអង្រឹង រួចធ្វើដំណើរជាមួយគ្នាទៅមុខបន្តទៀត។ គ្រាន់តែខ្ញុំបានចេញពីក្នុងអង្រឹងមិនបានប៉ុន្មានផង ក៏មានគ្រាប់ផ្លោងធ្លាក់ចំផ្លូវដែលពួកយើងបានធ្វើដំណើរឆ្លងកាត់។

- ក្រោយមកទៀតនៅពេលប្រទេសជាតិរំដោះ ខ្ញុំបានចុះសួរសុខទុក្ខកងទ័ព និងប្រជាពលរដ្ឋដែលរស់នៅខេត្តកំពង់ធំ វាអាចថាជានិស្ស័យក៏ថាបាន គឺបានបណ្តាលចិត្តឲ្យខ្ញុំចូលទៅកាន់មួយគឺ វត្តល្មៀក ។ ពេលនោះខ្ញុំក៏បានជួប និងថ្វាយបង្គំ លោកតា កើត វ៉ាយ គឺជាព្រះចៅអធិការ គ្រាន់តែខ្ញុំថ្វាយបង្គំ ភ្លាមលោកតា កើត វ៉ាយ ក៏បានមានសង្ឃដីការសួរមកខ្ញុំថា តើចៅនៅចាំលោកតាបានទេ? ពេលលោកតាមានសង្ឃដីការមិនទាន់ជឿនៅឡើយទេ មិនដឹងថាលោកមានសង្ឃដីការមានន័យយ៉ាងដូចម្តេចទេ? ព្រោះមិនដែលបានជួបលោក? បន្ទាប់មកលោកបានមានសង្ឃដីការបន្តទៀត ដោយបានរៀបរាប់អំពីហេតុការណ៍នៅភូមិកំពង់ថ្ម ស្រុកស្ទោង ខេត្ត

កំពង់ធំ និងរឿងបាយពំនូត ៣ដុំតូចៗ ដែលតាឲ្យនៅក្នុងព្រៃ។

សរុបអភូតហេតុ ដែលកើតឡើងសម្រាប់ជីវិតរបស់ខ្ញុំប្រហែលជាក្តួយៗ មិនជឿទេ សរុបសេចក្តី មកប្រសិនបើអាយុមិនអស់ គឺយើងមិនស្លាប់នោះទេ។

## ៤. ការធ្វើដំណើរទៅកាន់ខេត្តសៀមរាប

- នៅដើមឆ្នាំ១៩៧៣ អង្គភាពរបស់ខ្ញុំបានចល័តទ័ពពីខេត្តកំពង់ធំទៅកាន់ខេត្តសៀមរាប អង្គភាពឈរជើងនៅស្រុកស្ទោង អស់រយៈពេល ៣ខែ រួចហើយបានបន្តដំណើរទៅកាន់ស្រុកកំពង់ក្តី និងឈរជើងនៅជិតស្ពានកំពង់ក្តី ដែលជាស្ពានបុរាណ (នៅពេលនោះមានរថក្រោះ រថយន្ត ធុនធ្ងន់ដឹកកងទ័ពធ្វើដំណើរឆ្លងកាត់ស្ពាននោះ) ខ្ញុំក៏បានចុះពីលើរថយន្ត លើកដៃសំពះ បួងសួង និងសុំខមាលទោស ឈរក្បែរក្បាលនាគបុរាណនៅក្បាលស្ពានកំពង់ក្តី ខ្ញុំបានបន់ស្រន់ថា សូមឲ្យមានសន្តិភាព ចប់សង្គ្រាមឆាប់ៗ និងសូមឲ្យលោកយាយ លោកតា ពុក ម៉ែ បងប្អូននៅខាងក្រោយបានសុខសប្បាយ (ហើយក៏បានបួងសួងសុំឲ្យខ្លួនឯងឆាប់បានត្រលប់ទៅកាន់ស្រុកកំណើតវិញផងដែរ)។

- ពេលនោះក៏ទទួលបានផែនការថ្មី ដោយត្រូវធ្វើដំណើរពីកំពង់ក្ដី ទៅឈរជើងនៅក្នុងបរិវេណប្រាសាទអង្គរវត្តវិញ។ ពេលយប់សម្រាកនៅកន្លែងព្រះរយព្រះពាន់ ខ្ញុំបានធ្វើការបួងសួង លើកដៃសំពះដឹងគុណបុព្វបុរស ព្រលឹងដូនតាសូមជួយឲ្យប្រទេសជាតិបានទទួលសុខសន្តិភាព។
- អំឡុងពេលនៅសៀមរាប អង្គភាពខ្ញុំត្រូវបានចាត់តាំងឲ្យទទួលនិងការពារ នៃដំណើរយាងបំពេញទស្សនៈកិច្ច ចុះសួរសុខទុក្ខកងទ័ព រំដោះ របស់ **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ និងសម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** នៅខែមីនា ឆ្នាំ ១៩៧៣ ។
- ប៉ុន្តែផែនការរំដោះខេត្តសៀមរាបត្រូវបានបរាជ័យ ដោយសារសត្រូវមានកម្លាំងទ័ពច្រើន កងទ័ពយើងបង្ខំចិត្តត្រូវដកថយទៅប្រាសាទបន្ទាយក្ដី ស្រះស្រង់ ព្រះដាកវិញ។
- ពេលដែលបោះទីតាំងនៅប្រាសាទបន្ទាយក្ដី គឺពួក លន់ នល់ បានបាញ់កាំភ្លើងពីលើខ្នងភ្នំបាក់ខែង ដោយបាញ់ផ្ទក់តម្រង់មកលើកងទ័ពរំដោះ និងផ្ទះប្រជាពលរដ្ឋនៅជុំវិញបរិវេណអង្គរ មានកងទ័ពយើងបានស្លាប់ របួសជាច្រើន

នាក់ (ពួកវាមិន ហ៊ានបាញ់ចូលប្រាសាទទេ ដោយសារតែខ្លាចអន្តរជាតិ ថ្កោលទោស)។ ចំណែកឯអ្នករបួសត្រូវបានបញ្ជូនតាមវង់តូច មិនអាចតាមវង់ធំបានទេ ដើម្បីសុវត្ថិភាពរបស់ទ័ព។

## ៥. ការធ្វើដំណើរត្រឡប់មកពីខេត្តសៀមរាប

- ដោយសភាពការណ៍ប្រែប្រួល ទើបអង្គភាពរបស់ខ្ញុំបានត្រឡប់មកកាន់ខេត្តក្រចេះវិញ។ នៅពេលធ្វើដំណើរមកដល់ស្ពានកំពង់ថ្ម ក៏បានជួបជាមួយទាហាន លន់ នល់ ២នាក់ឆ្លងកាត់ស្ពាននោះផងដែរ។ ត្រង់ចំណុចនេះ ខ្ញុំនៅចាំមិនភ្លេចទេ គឺមានកងទ័ពយើងចំនួន ០២រូប បានពលី ជីវិតក្នុងការប្រយុទ្ធជាមួយទាហាន លន់ នល់ ។

## ៦. ការធ្វើដំណើរទៅកាន់ប្រទេសវៀតណាម ដោយឆ្លងកាត់ ខេត្តក្រចេះ

- នៅឆ្នាំ១៩៧៣ អង្គភាព២០៣ បានបោះទីតាំងក្នុងបរិវេណប្រាសាទបន្ទាយក្តី។ បន្ទាប់មក ក៏មានពិធីផ្ទេរកងទ័ពផងដែរ គឺបានរៀបចំនៅក្រៅបរិវេណប្រាសាទបន្ទាយក្តី និងស្រះស្រង់។ ពេលនោះ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅបន្តការរៀនសូត្រលើកកម្ពស់មុខវិជ្ជាពេទ្យ។

- នៅចុងឆ្នាំ១៩៧៤ អង្គភាពត្រូវចល័តទ័ពចេញពីកំពង់ធំ ឆ្លងតាមស្រុកចំការលើ ស្ទឹងត្រង់ ក្រូចឆ្មារឆ្ពោះទៅស្រុក ស្នួល សំដៅឆ្លងទៅវៀតណាម។ ពេលទៅដល់ស្រុកក្រូចឆ្មារ ខ្ញុំមានអារម្មណ៍ថា នឹកស្រុកណាស់ តែមិនអាចទៅបាន ព្រោះមិនទាន់ចប់ភារកិច្ច។ រួមដំណើរជាមួយខ្ញុំពេលនោះ មានសមមិត្ត ផៃ សមមិត្ត លី សមមិត្ត ខន (ប្រពន្ធ ង៉ូវ មិន) សមមិត្ត ឡាញ់ សមមិត្ត ឈឿន សមមិត្ត គីម ឡាង សមមិត្ត ពេជ្រ គីមហុង (ហៅកេន)។ ត្រូវស្នាក់នៅជំរំ បណ្តោះអាសន្ននិងមានការទំនាក់ទំនងពីអង្គភាពនៅវៀត ណាម គឺ ២ សប្តាហ៍ ក្រោយទើបមានរថយន្តមកទទួល បន្តដំណើរទៅទៀត។
- ខ្ញុំសូមបញ្ជាក់ថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជា ពលរដ្ឋកម្ពុជា ជាអ្នកបង្កើតឡើងនូវជ័យជំនះ បានក្លាយ ជាជនរងគ្រោះ នៃរបបប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី ដ៏ឃោឃៅ ។
- នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ពួក ប៉ុល ពត បាន ចេញគោលការណ៍៨"ខ" ដែលមានជាអាទិ៍ (១).ជម្លៀស ប្រជាជនទាំងអស់ឲ្យចេញពីក្រុងភ្នំពេញ (២).លុបបំបាត់ ទីផ្សារ (៣).លុបបំបាត់ការប្រើប្រាស់និងចរាចររូបិយបណ្ណ

(៤).ចាប់ផ្សឹកលោកសង្ឃទាំងអស់ និងបញ្ជូនឲ្យទៅនៅជនបទដើម្បីធ្វើពលកម្មបង្កបង្កើនផល (៥).ប្រហារជីវិតអ្នករដ្ឋការ នាយទាហាន ពលទាហាននៃរបប លន់ នល់ (៦).បង្កើតសហករណ៍ក្នុងទូទាំងប្រទេស (៧).បណ្តេញជនជាតិវៀតណាមទាំងអស់ចេញពីប្រទេសកម្ពុជា និង (៨).បញ្ជូនទ័ពទៅព្រំដែននៃបណ្តាប្រទេសជិតខាង ពិសេសព្រំដែនវៀតណាម។

- ក្នុងពេលដែលកំពុងរៀនសូត្រនោះ ខ្ញុំទទួលបានដំណឹងថា ក្នុងខែឧសភា ឆ្នាំ១៩៧៥ នៅភូមិភាគឦសានកម្ពុជា មានការកកើតឡើងនូវបណ្តាក្រុមផ្តាច់ខ្លួន ដែលធ្វើសកម្មភាពប្រឆាំងរដ្ឋអំណាច ប៉ុល ពត ក្នុងស្រុកតាវែង (៥៥A) ស្រុកវើនសៃ(ខេត្តរតនគិរី) ដឹកនាំដោយ លោក ប៊ុន មី លោក ប៊ូ ថង លោក ថង បៃ និងលោក ខាំ ផៃ បណ្តាអ្នកដែលផ្តាច់ខ្លួននោះ បានប្រមូលផ្តុំកម្លាំងដើម្បីដំណើរការកសាងមូលដ្ឋានអូពឹងដែលជាប់នឹងព្រំដែនវៀតណាម។ ក្នុងខែសីហា ឆ្នាំ១៩៧៥ កម្មាភិបាល និងយុទ្ធជនក្នុងភូមិភាគឦសានដែលមានជាអាទិ៍ លោក នូ បេង លោក ខាំ ឡៃ លោក ខាំ ផៃ បានភៀសខ្លួនទៅប្រទេសឡាវ។ លោក ប៊ូ ថង លោក ស៊ើយ កែវ លោក ថង បៃ

បានភៀសខ្លួនទៅប្រទេសវៀតណាម(ខេត្តហ្សាឡាយ-កុងទុំ) ដើម្បីបញ្ចៀសការកាប់សម្លាប់របស់ពួក ប៉ុល ពត អៀង សារី។ ឯកម្លាំងដែលនៅសេសសល់នៅក្នុងស្រុក មាន លោក ប៊ុន មី ជាអ្នកទទួលខុសត្រូវ និងបានកសាងទីតាំងនៅតាយ៉ាក។

- ជាមួយនោះ ខ្ញុំក៏បានដឹងថា ក្នុង**ឆ្នាំ១៩៧៤** លោក សាយ ភូថង សមាជិកគណៈកម្មាធិការបក្សខេត្តកោះកុង លោក ទៀ បាញ់ និង លោក រ៉ុង ផ្លាមកែសន រួមជាមួយយុទ្ធជនប្រមាណ ៣០០នាក់ បានកប់អាវុធនៅក្នុងព្រៃ និងភៀសខ្លួនទៅតំបន់ព្រំដែនប្រទេសថៃ ដើម្បីកសាងមូលដ្ឋានតស៊ូប្រឆាំងពួក ប៉ុល ពត - អៀង សារី។
- នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ **សម្តេចតេជោ ហ៊ុន សែន** បានយកជីវិតធ្វើជាដើមទុន ចេញដំណើរពីតំបន់កោះថ្ម x16 ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ឆ្ពោះទៅប្រទេសវៀតណាម ដើម្បីស្វែងរកមាគ៌ាសង្គ្រោះជាតិនិងប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។
- នៅខែកញ្ញា ឆ្នាំ១៩៧៧ ខ្ញុំទទួលបានដំណឹងថា **សម្តេចតេជោ ហ៊ុន សែន** ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ 7A របស់យោធភូមិភាគទី៧ នៃកងទ័ពប្រជាជន

វៀតណាម ពេលនោះខ្ញុំជាមួយនឹង ឯកឧត្តម ជា សារ៉ន បានជិះកង់ចម្ងាយ ១០គីឡូម៉ែត្រ ទៅសួរសុខទុក្ខ **សម្តេចតេជោ**។

- ក្នុងជំនួប **សម្តេចតេជោ ហ៊ុន សែន** បាននិយាយប្រាប់យើងខ្ញុំអំពីសភាពការណ៍ក្នុងប្រទេសកម្ពុជា អំពីគោលដៅតស៊ូដោយត្រូវកសាងកម្លាំងយោធា និងនយោបាយដើម្បីធ្វើជាបង្អែក និងដឹកនាំប្រជាជនកម្ពុជាក្រោកឈរឡើងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ដោយមានការជួយឧបត្ថម្ភរបស់កងទ័ពស្ម័គ្រចិត្តវៀតណាម។
- លោកបានផ្តាំផ្ញើយើងខ្ញុំឲ្យខិតខំរៀនសូត្រ ពិសេសត្រូវបង្កើនសាមគ្គីភាព និងសហការល្អជាមួយមិត្តវៀតណាមក្នុងការចុះជួយជនភៀសខ្លួនកម្ពុជាដែលកំពុងជ្រកកោនក្នុងបណ្តាខេត្តនៅភាគខាងត្បូងប្រទេសវៀតណាម (ពេលនោះខ្ញុំបានចុះជួយព្យាបាលបងប្អូនភៀសខ្លួនដែលរស់នៅវៀតណាម) ព្រមទាំងត្រូវត្រៀមលក្ខណសម្បត្តិសហការជាមួយមិត្តដើម្បី កសាងបណ្តាអង្គភាពពេទ្យយោធាសម្រាប់បដិវត្តន៍កម្ពុជានាពេលខាងមុខ ដើម្បីជួយសង្គ្រោះប្រជាជន។

- ក្រោយជំនួបជាមួយ **សម្ដេចតេជោ ហ៊ុន សែន** ជាបណ្ដើរៗ ខ្ញុំបានក្លាយទៅជាអ្នកនយោបាយដោយមិនដឹងខ្លួន (ទាំងក្នុងកងទ័ព ទាំងក្នុងអង្គការមហាជន ទាំងក្នុងបក្ស)
- នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ «កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា» ត្រូវបានបង្កើតឡើងក្រោមការដឹកនាំបញ្ជាដោយផ្ទាល់របស់ **សម្ដេចតេជោ ហ៊ុន សែន** ។
- នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានបង្កើតឡើង ដែលមាន **សម្ដេច ហេង សំរិន** ជាប្រធាន **សម្ដេច ជា ស៊ីម** ជាអនុប្រធាន **សម្ដេចតេជោ ហ៊ុន សែន** ជាសមាជិកនិងបានប្រកាសនូវគោលការណ៍ **១១ "ខ"** ដែលជាទង់ដឹកនាំប្រជាជនកម្ពុជាក្រោកឡើងផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ដណ្ដើមបានជ័យជម្នះនាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បើកចេញនូវសករាជមួយថ្មីគឺ សករាជនៃឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល។

## ៧. ដំណាក់កាលក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩

- ការតស៊ូដើម្បីរំដោះប្រជាជន រំដោះប្រទេសជាតិ វាជាបញ្ហាលំបាកណាស់ទៅហើយ ប៉ុន្តែការការពាររដ្ឋអំណាច និងធ្វើឲ្យប្រទេសឈានឡើងវាកាន់តែលំបាកជាង ហើយសំខាន់ទៅទៀត គឺការត្រូវគ្រប់គ្រងរដ្ឋអំណាចក្នុងសភាពការណ៍សង្គមទាំងមូលច្របូកច្របល់ ជួរកម្មាភិបាលមានតិច ហើយខ្មាំងសត្រូវចិញ្ចឹមចិត្តវាយបកដណ្តើមរដ្ឋអំណាចវិញ។ ការលំបាកនេះវាមានច្រើនលើសលប់ បើប្រៀបធៀបនឹងការងាយស្រួល។
- ក្នុងដំណាក់កាល១៩៧៩-១៩៨០៖ ខ្ញុំមានភារកិច្ចជាច្រើនដែលត្រូវបំពេញ ក្នុងឋានៈជាប្រធានស្នងការចាត់តាំងកងទ័ព។ ជាក់ស្តែងគឺ៖

- ក្នុងខែកក្កដា ឆ្នាំ១៩៧៩ ខ្ញុំបានចូលរួមការងារជ្រើសរើសកម្មាភិបាលដឹកនាំនិងរៀបចំបង្កើតក្បាលម៉ាស៊ីនខុទ្ទកាល័យក្រសួងការពារប្រទេស អគ្គសេនាធិការ អគ្គស្នងការនយោបាយ អគ្គស្នងការភស្តុភារ-បច្ចេកទេស។
- ចូលរួមការងារចាត់តាំងកសាងសាលាទ័ពជើងគោក សាលាបច្ចេកទេសនិងសាលាភស្តុភារ បើកវគ្គបណ្តុះបណ្តាលនយោបាយនិងបំពាក់បំប៉នមុខជំនាញ និងបំពេញវិជ្ជា។

- ក្រោយថ្ងៃរំដោះ កម្ពុជាកសាងបាន ៣០ កងវរសេនាតូច ដែលបង្កើតបាន៤កងពលតូច។ ពេលនោះ ខ្ញុំបានចូលរួមការងារចាត់តាំងកសាងក្បាលម៉ាស៊ីនយោធាក្រុងភ្នំពេញ (មេបញ្ជាការគឺសមមិត្ត ញឹក ហួន) កងពលតូចលេខ២ (មេបញ្ជាការគឺសមមិត្ត ទី ង៉ូ) កងពលតូចលេខ៣ (មេបញ្ជាការគឺសមមិត្ត ព្រុំ ថាវ) កងពលតូចលេខ៤ (មេបញ្ជាការគឺសមមិត្ត នាង សាបាន) និងបណ្តាកងវរសេនាតូចចំណុះ។
- ខ្ញុំបានចូលរួមការងារជ្រើសរើសកម្មាភិបាលដែលមានសមត្ថភាព មានគោលជំហរនយោបាយល្អ ចេះបំផុសចលនាបដិវត្តន៍ទាំងបីរបស់ប្រជាជន ដើម្បីតែងតាំងឲ្យកាន់តួនាទីដឹកនាំក្នុងបណ្តាអង្គភាពទាំងកងទ័ពស្រួចទាំងកងទ័ពតំបន់។ ផ្តើមចេញពីនេះ ដើម្បីកសាងក្រុមស្នូលនិងពង្រីកបក្ស។
- ខ្ញុំក៏មិនដែលបានមើលរំលងចំពោះការងារគោលនយោបាយសមរភូមិក្រោយកងទ័ព។
- ជ្រើសរើស និងតែងតាំងកម្មាភិបាលទទួលបន្ទុកការងារយុវជន ការងារនារីក្នុងកងទ័ពដែលជាថ្នាលសម្រាប់កសាងក្រុមស្នូលនិងពង្រីកបក្សក្នុងកងទ័ព។

- ស្វែងរកនិងជ្រើសរើសអ្នកមានសមត្ថភាពនិងគោលជំហរល្អ ដើម្បីបញ្ជូនទៅសិក្សានៅសហភាពសូវៀត អាឡឺម៉ង់ និងវៀតណាមជាដើម។
- ខ្ញុំចង់បញ្ជាក់ថា ៖ ក្នុងការជ្រើសរើសកម្មាភិបាលកងទ័ព ដើម្បីបញ្ជូនទៅសិក្សារៀនសូត្រនៅក្រៅប្រទេស យើងមានការលំបាកខ្លះៗ ព្រោះថា បងប្អូនមិនចង់ឃ្លាតឆ្ងាយពីក្រុមគ្រួសារដែលទើបបានជួបជុំគ្នាក្រោយថ្ងៃរំដោះឡើយ ហើយចង់បន្តបំពេញភារកិច្ចប្រយុទ្ធវាយខ្មាំងនៅលើសមរភូមិ។ ពេលនោះខ្ញុំបានអប់រំបងប្អូនថា "ត្រូវចាត់ទុកការងារសិក្សារៀនសូត្រ ជាភារកិច្ចរបស់កងទ័ព"។
- ក្នុងដំណាក់កាល១៩៨០-១៩៨២ ៖ ខ្ញុំមានភារកិច្ចជាច្រើនដែលត្រូវបំពេញ ក្នុងឋានៈជាអនុប្រធានសមាគមនារីសង្គ្រោះជាតិកម្ពុជា។ ខ្ញុំបានដឹកនាំការងារនារីក្នុងបរិការណ៍ដែលប្រទេសជាតិមានសន្តិភាពផង និងមានសង្គ្រាមផង។ ខ្លឹមសារសំខាន់ៗនៃការងារចលនានារីដែលខ្ញុំត្រូវបំពេញក្នុងដំណាក់កាលនេះរួមមាន៖
- ដឹកនាំការងារឃោសនាអប់រំឲ្យបងប្អូននារីបានយល់ច្បាស់និងចូលរួមការអនុវត្តសិទ្ធិស្មើភាពរវាងបុរសនិងនារី ហើយពង្រីកកម្លាំងនិងលទ្ធភាពដ៏ធំធេងរបស់នារីកម្ពុជា

ក្នុងសកម្មភាពគ្រប់គ្រងរដ្ឋ គ្រប់គ្រងសង្គម គ្រប់គ្រងសេដ្ឋកិច្ច វប្បធម៌ និងការកសាងគ្រួសារសុភមង្គល កសាងមនុស្សថ្មីនៃរបបថ្មី។

- ធ្វើជាសេនាធិការជូនបក្ស និងរដ្ឋក្នុងការកសាងគោលនយោបាយរបស់បក្សនិងរដ្ឋចំពោះបងប្អូននារី ដោយយកចិត្តទុកដាក់គិតគូរដល់ជីវភាពរស់នៅ និងសុខភាពរបស់នារីនិងកុមារជាពិសេសគឺចំពោះនារីមេម៉ាយនិងកុមារកំព្រា។ ជាជំហានៗដោះស្រាយឲ្យបានល្អថែមទៀតនូវរាល់មធ្យោបាយ ធ្វើការងារ រៀនសូត្រ រស់នៅ របបសម្រាកលំហែកាយព្យាបាលជំងឺ សម្រាលកូននិងបីបាច់ថែរក្សាកូន ពិសេសគឺសម្រាប់នារីនៅជនបទ នារីជាកម្មករនិងនៅតំបន់ជនជាតិភាគតិច ។
- ដឹកនាំសមាគមនារីឲ្យពង្រឹងនិងពង្រីកក្បាលម៉ាស៊ីនអង្គការចាត់តាំងរបស់ខ្លួនបានទូលំទូលាយពីមជ្ឈិមដល់មូលដ្ឋាន ដើម្បីប្រមែប្រមូលនារីដ៏ច្រើនកុះករឲ្យចូលរួមក្នុងបុព្វហេតុបដិវត្ត។ អប់រំឲ្យបងប្អូននារីយល់ច្បាស់ថែមទៀតពីទំនាក់ទំនងដ៏ស្អិតរមួតរវាងការរំដោះនារី និងកិច្ចការពារកសាងមាតុភូមិ មើលឃើញច្បាស់នូវភារៈទទួលខុសត្រូវរបស់នារីចំពោះមាតុភូមិ ចំពោះសង្គមនិងគ្រួសារ ។

- ដឹកនាំយ៉ាងសកម្មនូវចលនាប្រឡងប្រណាំង៥ល្អរបស់នារី លើកទឹកចិត្តចំពោះតួនាទីរបស់នារីក្នុងចលនាបដិវត្តទាំងបីរបស់មហាជន ចលនាអំពាវនាវជនវង្វេងផ្លូវឲ្យត្រឡប់មកវិញនិងក្នុងចលនាផលិតកម្ម ដើម្បីស្តារប្រទេសជាតិ ។
- ខ្ញុំចង់បញ្ជាក់ :
- **ចលនាបដិវត្តន៍ទាំងបី**របស់ប្រជាជនគឺ (១).កសាងកម្លាំងពិតបដិវត្តន៍ (២).បង្កបង្កើនផលស្ថិរកម្មជីវភាពរស់នៅ (៣).វាយខ្ទាំងការពារភូមិ-ឃុំ និងអូសទាញជនវង្វេងផ្លូវ ។ ពេលនោះ គឺមានកម្មវិធីអូសទាញតាមរយៈសំឡេងខ្លុយ តាមវិទ្យុកងទ័ព (លើកពីគំរូវីរភាពរបស់នារី សេក ស ......)
- **ចលនានារី៥ល្អ**គឺ (១) ស្នេហាជាតិ និងប្រជាជន៖ ការចូលរួមចំណែកយ៉ាងសកម្មក្នុងការការពារ និងកសាងប្រទេសជាតិតាមរយៈភារកិច្ចរៀងៗខ្លួន (២)ការងារផលិតកម្ម និងសេដ្ឋកិច្ច៖ ការខិតខំប្រឹងប្រែងបង្កបង្កើនផល ធ្វើពាណិជ្ជកម្ម ឬបំពេញការងារអង្គភាព ដើម្បីលើកកម្ពស់ជីវភាពគ្រួសារ (៣) សីលធម៌ និងការរស់នៅ៖ ការរក្សាបាននូវកិត្តិយស សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាល្អ និង

វប្បធម៌ប្រពៃណីខ្មែរ (៤) ការថែទាំសុខភាព និងអនាម័យៈ ការយកចិត្តទុកដាក់ខ្ពស់ចំពោះសុខភាពផ្ទាល់ខ្លួន គ្រួសារ ជាពិសេសគឺការចេះរៀបចំលំនៅឋានឲ្យមានអនាម័យ (៥) ការអប់រំ និងការសិក្សាៈ ការខិតខំរៀនសូត្រដើម្បី បង្កើនចំណេះដឹងទូទៅ និងការចូលរួមអប់រំកូនចៅឲ្យ ក្លាយជាទំពាំងស្នងឫស្សីដ៏ល្អ។

- គោលបំណងចម្បងនៃចលនានេះ គឺដើម្បីលុបបំបាត់ភាព អសកម្ម និងផ្តល់តម្លៃដល់ស្ត្រីក្នុងការកសាងសង្គមគ្រួសារ និងសង្គមជាតិ។
- ក្នុងដំណាក់កាលនេះ ខ្ញុំជាសមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិម ជាសមាជិករដ្ឋសភាមណ្ឌលបាត់ដំបង និង ជាអនុប្រធានសមាគមនារីសង្គ្រោះជាតិកម្ពុជាផង។ ដូច្នេះ ខ្ញុំត្រូវបំពេញភារកិច្ចទាំងក្នុងក្របខណ្ឌការងារបក្ស ទាំងក្នុងក្របខណ្ឌការងាររដ្ឋសភា និងក្នុងក្របខណ្ឌ ការងារអង្គការមហាជន។ ភារកិច្ចទាំងបី នេះ គឺផ្សារភ្ជាប់ បេះមិនដាច់ជាមួយប្រជាជននិងមូលដ្ឋាន។



*សមមិត្ត ម៉ែន សំអន ថ្លែងសុន្ទរកថា ក្នុងទិវាអបអរសាទរ ទិវានារីអន្តរជាតិ ៨ មីនា ១៩៨០*

- **ដំណាក់កាល១៩៨១-១៩៨៥ ៖** ក្នុងដំណាក់កាលនេះ ការងារដែលខ្ញុំត្រូវរែកពុនមានទំហំធំណាស់ ដោយខ្ញុំបានទទួលនូវតំណែងជាប្រធានគណៈឃោសនាអប់រំមជ្ឈិមបក្សបន្ថែមពីលើតំណែងជាសមាជិករដ្ឋសភា។

- ក្នុងដំណាក់កាលនេះ មានព្រឹត្តិការណ៍ចំនួន៣ ដែលខ្ញុំមិនអាចភ្លេចបានគឺ ៖

ទី១. សម័យប្រជុំលើកទី៥ នីតិកាលទី១ រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា( ១៥-១៨/៨/១៩៨៣ ) បានអនុម័តយកថ្ងៃ២០ ខែឧសភាជារៀងរាល់ឆ្នាំ ជាទិវាប្រជាជនទាំងមូលចងកំហឹងចំពោះឧក្រិដ្ឋកម្មប្រល័យពូជ

សាសន៍ដែលរបប ប៉ុល ពត បានបង្កឡើងចំពោះប្រជាជន និងប្រជាជាតិកម្ពុជាទាំងមូល។ រហូតមកដល់ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៨ ក៏បានកំណត់ថាជា «**ទិវាជាតិនៃការចងចាំ**» វិញ។

ទី២. សម័យប្រជុំលើកទី៨ នីតិកាលទី១ រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា( ១០-១៤/១/១៩៨៥ ) បានបោះឆ្នោតជ្រើសតាំង**សម្តេចតេជោ ហ៊ុន សែន** ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី ដោយមានសំឡេងគាំទ្រ ១00%។

ទី៣. មហាសន្និបាតតំណាងទូទាំងប្រទេសលើកទី៥ របស់បក្សប្រជាជនបដិវត្តន៍កម្ពុជា ត្រូវបានប្រព្រឹត្តទៅពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៨៥។ ខ្ញុំត្រូវបានមហាសន្និបាតបោះឆ្នោតជ្រើសតាំងជាសមាជិកគណៈកម្មាធិការមជ្ឈិម និងជាប់ឆ្នោតជាសមាជិកការិយាល័យនយោបាយ សមាជិកគណៈលេខាមជ្ឈិម ទទួលភារកិច្ចជាប្រធានគណៈឃោសនាអប់រំមជ្ឈិមនៅពេលដែលខ្ញុំទើបតែមានអាយុ៣២ឆ្នាំប៉ុណ្ណោះ។

- ក្នុងឋានៈជាប្រធានគណៈឃោសនាអប់រំមជ្ឈិម ខ្ញុំបានរួមចំណែកដឹកនាំស្ថាប័នមួយនេះបំពេញសម្រេចនូវតួនាទីជា

សេនាធិការ និងជាជំនួយការឲ្យគណៈកម្មាធិការមជ្ឈិមបក្ស ហើយដោយផ្ទាល់និងជាប់ជាប្រចាំគឺការិយាល័យនយោបាយនិងគណៈលេខា អំពីមាគ៌ា គោលការណ៍ គោលនយោបាយធំៗរបស់បក្សក្នុងវិស័យឃោសនាអប់រំ និងបំផុសចលនាមហាជន ; ក្នុងវិស័យការងារកសាងបក្ស អំពីនយោបាយ សតិអារម្មណ៍ សីលធម៌ ចំណងទាក់ទង ផ្សារសាច់ផ្សារឈាមរវាងបក្សនិងប្រជាជន ; ព្រមទាំងជាស្ថាប័នជំនាញអំពីការងារឃោសនាអប់រំនិងចលនាមហាជនរបស់បក្ស។

- **ដំណាក់កាល ១៩៨៥ - ១៩៨៩ ៖** ក្នុងឋានៈជាសមាជិកការិយាល័យនយោបាយ សមាជិកគណៈលេខាមជ្ឈិម ខ្ញុំបានទទួលភារកិច្ចថ្មីជាប្រធានគណៈចាត់តាំងមជ្ឈិម។

- ខ្ញុំជាប្រធានស្ថាប័នដែលជាសេនាធិការរបស់គណៈកម្មាធិការមជ្ឈិមបក្ស ដោយផ្ទាល់គឺការិយាល័យនយោបាយ និងគណៈលេខា អំពីការងារកសាងបក្ស កសាងកម្មាភិបាលបក្ខជន និងការងារការពារនយោបាយ ផ្ទៃក្នុងបក្ស។
- ដឹកនាំ ឬសហការសិក្សាស្រាវជ្រាវ និងលើកសំណើអំពីបណ្តាបញ្ហាសំខាន់ៗដូចជា គោលការណ៍ គោលនយោបាយ និងគ្រោងរៀបចំការងារកសាងរចនាសម្ព័ន្ធ

អង្គការចាត់តាំងរបស់បក្ស រដ្ឋ អង្គការមហាជននៅស្ថាប័នទាំងនេះ។

- ណែនាំ និងត្រួតពិនិត្យការអនុវត្តបណ្តាសេចក្តីសម្រេចចិត្ត និងសារាចររបស់បក្ស ស្តីពីការងារចាត់តាំងកសាងបក្ស នៅបណ្តាគណៈកម្មាធិការបក្ស និងអង្គការបក្សចំណុះមជ្ឈិមផ្ទាល់។ វាយតម្លៃកម្មាភិបាលមុនពេលស្ថាប័នមានសមត្ថកិច្ច សម្រេចតែងតាំងឲ្យកាន់តំណែងជាអ្នកដឹកនាំ។

- ខ្ញុំចង់បញ្ជាក់ ៖

- ក្នុងឆ្នាំ១៩៨៥ ប្រព័ន្ធអង្គការចាត់តាំងរបស់បក្សត្រូវបានពង្រឹង ហើយចំនួនបក្ខជនក៏បានកើនឡើងយ៉ាងឆាប់រហ័ស។ ក្នុង២០ខេត្ត-ក្រុងសុទ្ធតែមានគណៈកម្មាធិការបក្សខេត្តនិងគណៈកម្មាធិការបក្សក្រុងបណ្តោះអាសន្ន។ គ្រប់ស្រុកមានសាខាបក្សដឹកនាំ ក្នុងនោះស្រុកចំនួន៤០/១៥២ មានគណៈកម្មាធិការបក្សស្រុកបណ្តោះអាសន្ននិង៧១ស្រុកមានបក្ខជនពី១៥នាក់ឡើងទៅ។ នៅថ្នាក់ឃុំរួមមាន៖ ១២៤ឃុំមានសាខាបក្សដឹកនាំ និង២៣៥ឃុំមានបក្ខជនពី១-២នាក់។ បណ្តាភូមិ-ឃុំសុទ្ធតែបានកសាងឡើងនូវមូលដ្ឋាននយោបាយនិងរដ្ឋអំណាចបដិវត្តន៍។ ក្នុងទូទាំងប្រទេសមានសាខាចំនួន៨៩៥សាខា និងមានបក្ខ

ជនចំនួន៩.៩៨០នាក់ ក្នុងនោះសាខាកើនឡើង៥៥២ សាខា បក្ខជនកើនឡើង៥.១១០នាក់ បើបៀបនឹងឆ្នាំ ១៩៨៤។ លទ្ធផលនៃការងារកសាងបក្សដូចបានពោល ខាងលើនេះ គឺជាព្រឹត្តិការណ៍នយោបាយមួយមាន អត្ថន័យយ៉ាងសំខាន់ដែលបានកត់សម្គាល់នូវជំហានឈាន ឡើងរបស់បដិវត្តន៍កម្ពុជា។

- ការងារពង្រីកបក្សបានតម្រង់ឆ្ពោះទៅរកមូលដ្ឋាន ធ្វើឲ្យ ដំណើរកសាងបក្សជាជំហានៗសមស្របទៅនឹងក្រឹត្យក្រម។ ចាប់ពីមានបក្ខជនដ៏តិចតួចនាថ្ងៃរំដោះ ៧ មករា ១៩៧៩ មកទល់ខែកុម្ភៈ ឆ្នាំ១៩៨៩ យើងមានបក្ខជន២៥.១៦០នាក់ ឃុំ៦៧% កងវរសេនាតូចនិងយោធាស្រុក៩០% រោង ចក្រនិងសហគ្រាស ៥៥លើ៦៩មានសាខាបក្ស។ បក្ខ ជនថ្នាក់ឃុំមាន៤.៦៤២នាក់ ត្រូវជា១៨% បក្ខជននៅ ភូមិមាន៥៦១នាក់។ ទន្ទឹមនោះ យើងមានសមាជិកក្រុម ស្នូលសរុប៦២.៦២៦នាក់ នៅថ្នាក់ឃុំ១៤.៥៨១នាក់ នៅភូមិ១៣.៥២៧នាក់។ យើងមានសម្ព័ន្ធយុវជនសរុប ៨០.៦៨៨នាក់។

- **ដំណាក់កាល១៩៨៩-១៩៩១៖** ជាសមាជិកការិយាល័យ នយោបាយ ខ្ញុំបានទទួលភារកិច្ចថ្មីជាប្រធានសហព័ន្ធ

សហជីពកម្មករកម្ពុជា។ ខ្ញុំទទួលខុសត្រូវដឹកនាំ និង សម្របសម្រួលសកម្មភាពការងារលើគ្រប់វិស័យរបស់ អង្គការសហជីពក្នុងនោះមាន ៖

- ចូលរួមកសាងគោលនយោបាយ ព្រមទាំងសហការជាមួយ បណ្ដាស្ថាប័នរដ្ឋ និងគណៈកម្មាធិការបក្សដើម្បីកសាង និងសុក្រឹតកម្មប្រព័ន្ធច្បាប់ដែលទាក់ទងទៅនឹងផល ប្រយោជន៍ សុខុមាលភាព និងសុវត្ថិភាពរបស់ពលករ។
- គ្រប់គ្រង និងពង្រីកអង្គការចាត់តាំង ក្នុងនោះមានការ ពង្រីកសមាជិកថ្មី បង្កើតសហជីពមូលដ្ឋាន កសាងជួរ កម្មាភិបាលសហជីពខ្លាំងក្លារឹងមាំ បញ្ចូលវិទ្យាសាស្ត្រ-បច្ចេកទេសក្នុងសកម្មភាពផលិតកម្ម។
- ដឹកនាំចាត់តាំងអនុវត្តនូវបណ្ដាសេចក្ដីសម្រេចចិត្ត ក៏ដូចជា ការកំណត់ទិសរបស់មហាសន្និបាតសហជីព និងរបស់ ការិយាល័យនយោបាយ។
- **ជាលទ្ធផល** ៖ ក្នុងឆ្នាំ១៩៩០ បានអប់រំនិងបំផុសចលនា ជាច្រើនក្នុងកម្មករ និយោជិក។ បានបង្កើតបន្ថែមនាទី ផ្សាយសំឡេងពលករតាមវិទ្យុមួយសប្ដាហ៍ម្ដងរៀងរាល់ ល្ងាចថ្ងៃសៅរ៍។ បើកមហាសន្និបាតសហជីពបានចំនួន ១១០ លើ ៧០០មូលដ្ឋាន ដើម្បីជ្រើសតាំងឡើងវិញក្បាលម៉ាស៊ីន

ដឹកនាំ និងកំណត់ទិសដៅភារកិច្ចសម្រាប់អាណត្តិថ្មី។ សមាជិកសហជីពទូទាំងប្រទេសមាន ១៦៩.៣៥៥នាក់ ក្នុងនោះពង្រីកថ្មីបាន២០៣៩នាក់។ ការផ្តល់ប័ណ្ណ សមាជិក សម្រេចបាន៩០% ពង្រឹងមួយកម្រិតការងារគ្រប់គ្រង សមាជិក សហជីព។

- ក្នុងនាមជាសមាជិករដ្ឋសភាមណ្ឌលបាត់ដំបងក្នុងសម័យ រដ្ឋកម្ពុជា(១៩៩១) អ្នកតំណាងរាស្ត្រមណ្ឌលស្វាយរៀង (ពីឆ្នាំ១៩៩៣តទៅ) និងក្នុងនាមជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ (១៩៩៩) ខ្ញុំត្រូវបំពេញការងារជាច្រើន ហើយមានព្រឹត្តិការណ៍ធំៗចំនួន៣ដែលខ្ញុំចងចាំមិនភ្លេចគឺ ៖
- **ទី១**, ក្នុងសម័យប្រជុំវិសាមញ្ញដែលត្រូវបានបញ្ចប់នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៩១ រដ្ឋសភាកម្ពុជាបានគាំទ្រគោលជំហររបស់ **សម្តេចតេជោ ហ៊ុន សែន** ដោយអះអាងថា នឹងផ្តល់ជូនអង្គការសហប្រជាជាតិនូវតួនាទីមួយដ៏សំខាន់ក្នុងការដោះស្រាយជម្លោះ ប្រសិនបើតួនាទីនោះស្របនឹងធម្មនុញ្ញអង្គការសហប្រជាជាតិ ស្របនឹងគោលការណ៍គោរពអធិបតេយ្យ និងសិទ្ធិស្វ័យសម្រេចរបស់ប្រជាជនកម្ពុជា។ តួនាទីរបស់អង្គការសហប្រជាជាតិត្រូវ

បានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ក្នុងនាមជាតំណាងនៃអធិបតេយ្យរបស់កម្ពុជា ជាអ្នកសម្រេច។ រដ្ឋសភាកម្ពុជាអះអាងនូវគោលជំហរទប់ស្កាត់ការបង្កើតឡើងវិញរបបប្រល័យពូជសាសន៍ ប៉ុល ពត រក្សាដដែលនូវស្ថានភាពខាងនយោបាយ និងយោធារហូតដល់ពេលដែលបង្កើតបានរដ្ឋាភិបាលថ្មី តាមរយៈ នៃការបោះឆ្នោតជាសកល។ ក្នុងឱកាសនេះ លោកប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីនៃរដ្ឋកម្ពុជា **ហ៊ុន សែន** បានថ្លែងសង្កត់ធ្ងន់ថា " ទោះបីខាងមុខមានការលំបាកយ៉ាងណាក៏ដោយ ប៉ុន្តែប្រការសំខាន់មិនមែនស្ថិតនៅត្រង់ថា ការលំបាកមានកម្រិតប៉ុនណានោះទេ គឺវាស្ថិតនៅត្រង់ថា តើយើងហ៊ានឆ្លងកាត់ដែរឬទេ។ ត្រូវកសាងឲ្យបានជាប់ជានិច្ចនូវទឹកចិត្តស្នេហាជាតិ ស្រឡាញ់ប្រជាជន និងស៊ូស្លាប់ជាជាងបាត់ឯករាជ្យ អធិបតេយ្យជាតិ។ ម្យ៉ាងទៀត ការចាត់តាំងនិងបំផុសឲ្យបានកម្លាំងសាមគ្គីប្រជាជនទាំងមូលឲ្យក្លាយជាថាមពល ដ៏ខ្លាំងក្លា គឺជាកិច្ចការត្រូវធ្វើជាប់ជាប្រចាំ។ ទាល់តែមានជំនឿលើខ្លួនឯង ជឿលើប្រជាជន និងរួមជាមួយប្រជាជន ប្រឹងប្រែងឆ្លងកាត់ការលំបាក ទោះបីស្ថិត

ក្នុងកាលៈទេសៈ ណាក៏ដោយ នោះទើបយើងអាចឈាន ដល់គោលដៅរបស់យើង″។

**ទី២**, ព្រះរាជាណាចក្រកម្ពុជាទី២ បានចាប់កំណើត ជាមួយនឹងការចាកចេញរបស់ UNTAC បន្ទាប់ពីបាន ចំណាយថវិកាប្រមាណ២ពាន់លានដុល្លារ តែកម្ពុជាបាន បន្តស្ថិតក្នុងស្ថានភាពប្រទេសមួយតំបន់គ្រប់គ្រង២ និង រដ្ឋាភិបាល២។ សង្គ្រាមនៅបន្តទាំងនៅព្រំដែនជាប់ ជាមួយប្រទេសថៃ និងតំបន់មួយចំនួននៅក្នុងប្រទេស ដែលមានលក្ខណៈជាស្ថានភាពស្បែកខ្លា...។ ខ្មែរក្រហម បន្តមានរដ្ឋាភិបាល មានប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី មាន វិទ្យុផ្សាយសំឡេង រហូតបោះពុម្ពក្រដាសប្រាក់សម្រាប់ ចាយនៅក្នុងតំបន់ដែល គេគ្រប់គ្រងថែមទៀត។ គេបាន តម្រូវឲ្យរាជរដ្ឋាភិបាលទទួលយកកម្មវិធីនយោបាយ អប្បបរមាជំនួសឲ្យរដ្ឋធម្មនុញ្ញថ្មី ក្នុងពេលជំនួបចរចា នៅទីក្រុងព្យុងយ៉ាងនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជា មានិតកូរ៉េ នាខែឧសភា ឆ្នាំ១៩៩៤ ហើយមិនព្រមទទួល យកនូវការឈប់បាញ់ដែលរាជរដ្ឋាភិបាលបានស្នើ និង សម្តេចព្រះសង្ឃរាជទាំងពីរគណៈបានបិណ្ឌបាតនោះ

ឡើយ។ គេជំរុញការវាយប្រហារមកលើប្រជាជនរហូតដល់សម្លាប់ជនជាតិបរទេសថែមទៀតផង។

- យុទ្ធសាស្ត្រច្រេះស៊ីដែករបស់ ប៉ុល ពត បានជួបជាមួយនយោបាយ «**ឈ្នះ - ឈ្នះ**» ដែលផ្តួចផ្តើមឡើងនិងដឹកនាំអនុវត្តផ្ទាល់ដោយសម្តេចតេជោ ហ៊ុន សែន គឺជាវគ្គផ្តាច់ព្រ័តនៃដំណាក់កាលបង្រួបបង្រួមជាតិរបស់កម្ពុជា។ ខ្លឹមសារពិតប្រាកដនៃនយោបាយ «**ឈ្នះ - ឈ្នះ**» នេះមានដូចតទៅ ៖ (១) : ការធានាចំពោះសន្តិសុខ ទាំងអាយុជីវិត ទាំងរូបកាយសម្រាប់មនុស្សទាំងអស់ ដែលស្ម័គ្រចិត្តផ្តាច់ខ្លួនពីអង្គការចាត់តាំងខាងនយោបាយ និងយោធារបស់ ប៉ុល ពត ហើយវិលមករួមរស់ជាមួយរាជរដ្ឋាភិបាល និងសង្គមជាតិវិញ (២) : ការរក្សាអាជីព និងមុខរបរជូនអ្នកទាំងនោះតាមរយៈការធ្វើសមាហរណកម្ម លើកលែងតែពួកមានមុខងារនយោបាយក្នុងរដ្ឋាភិបាល (៣) : ការរក្សាកម្មសិទ្ធិលើទ្រព្យសម្បត្តិជាអចលនទ្រព្យ និងចលនទ្រព្យរបស់មនុស្សគ្រប់រូបទាំងអស់ ។
- ការធានាទាំងបីយ៉ាងខាងលើ បានឆ្លើយតបយ៉ាងសមស្របចំពោះផលប្រយោជន៍របស់បងប្អូនដែលស្ថិតក្នុងជួរខ្មែរក្រហម និងប្រជាជនដែលស្ថិតក្នុងតំបន់ខ្មែរក្រហមកាន់កាប់

ហើយវាបានក្លាយទៅជាអាវុធដ៏ស័ក្តិសិទ្ធិដែលវាយសំពង ទៅលើនយោបាយសង្គ្រាមយោធា និងយុទ្ធសាស្ត្រ ប្រែះស៊ី ដែករបស់ខ្មែរក្រហម និងទីបំផុតអង្គការចាត់តាំងខាង នយោបាយ និងយោធារបស់ខ្មែរក្រហមក៏ត្រូវដួលរលំ រលាយទាំងស្រុង។

- សន្តិភាព និងការបង្រួបបង្រួមជាតិបានកើតមានទាំងស្រុង ការឯកភាពជាតិ ឯកភាពទឹកដី គ្មានតំបន់អបគមន៍ និង ការរួបរួមនៅក្រោមដំបូលនៃរដ្ឋធម្មនុញ្ញតែមួយ ព្រះមហាក្សត្រតែមួយអង្គ និងរាជរដ្ឋាភិបាលតែមួយ ត្រូវ បានកើតឡើងលើទឹកដីដ៏កម្សត់នេះ ដែលជាឱកាស ពេជ្រសម្រាប់ការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម តាម យុទ្ធសាស្ត្រត្រីកោណរបស់រាជរដ្ឋាភិបាល។
- កម្លាំងខ្មែរក្រហមដែលនៅសេសសល់បានចុះចូល និង វិលមករួមរស់ជាមួយរាជរដ្ឋាភិបាល ហើយមេដឹកនាំ ក្បាលរឹងធំៗមួយចំនួនទៀតត្រូវបានចាប់ខ្លួនដើម្បីឲ្យ តុលាការកាត់ទោសពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលពួកគេបានប្រព្រឹត្តកាលពីអតីតកាល។ ដូច្នេះអ្វី ដែលកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ចង់បានតែ UNTAC មិនអាចសម្រេចបាននោះ ឥឡូវនេះបានក្លាយ

ទៅជាតថភាពជាក់ស្តែងហើយ ពីព្រោះភាគីកម្ពុជាបានស្រុះស្រួលគ្នាដោយគ្មានការបង្គាប់បញ្ជា ឬការជំរុញពីខាងក្រៅ។

- **សម្តេចតេជោ ហ៊ុន សែន** មានប្រសាសន៍ថា "នយោបាយ «ឈ្នះ-ឈ្នះ» គឺជាស្នូល និងជាឧបករណ៍ដ៏សំខាន់បំផុតនៃទស្សនវិជ្ជាសន្តិភាពរបស់យើងខ្ញុំ ហើយវាក៏ជាមេរៀនដ៏សំខាន់បំផុតផងដែរ ដែលយើងដកស្រង់បានពីការសោកល្បង និងការតស៊ូយ៉ាងប្ដូរផ្ដាច់អស់រយៈពេលជាច្រើនទសវត្សរ៍ ដើម្បីឈានមកសម្រេចបាននូវសន្តិភាព និងភាពសុខក្សេមក្សាន្តយ៉ាងពេញលេញនាពេលនេះ។ ចំណុចគន្លឹះនៃនយោបាយ «ឈ្នះ - ឈ្នះ» គឺការទទួលស្គាល់ថា នៅក្នុងការធ្វើសង្គ្រាមបំផ្លិចបំផ្លាញប្រាកដជាមិនអាចមានអ្នកឈ្នះនោះទេ ហើយការចងអាឃាតព្យាបាទ ក៏មិនអាចនាំមកនូវសុខសន្តិភាពជូនប្រទេសជាតិ និងប្រជាជនបានដែរ"។
- "ការបញ្ចប់ដោយជោគជ័យ និងដោយសន្តិវិធីនូវសង្គ្រាម និងការបែកបាក់ជាតិ គឺពិតជាប្រការដែលសម្រេចបានមកដោយលំបាកជាទីបំផុត។ ក៏ប៉ុន្តែការធានានូវចីរភាពនៃសុខសន្តិភាព និងការពង្រឹងថែមទៀតនូវវប្បធម៌សន្តិភាព

ដែលសម្រេចបានមកនេះ គឺជាភារកិច្ចដែលរឹតតែលំបាកធ្ងន់ធ្ងរណាស់ទៅទៀត។ នៅក្នុងគោលដៅនេះ យើងត្រូវតែធ្វើការយ៉ាងស្វាហាប់ និងត្រូវខិតខំប្រឹងប្រែងទ្វេឡើងថែមទៀត ដើម្បីថែបំប៉នជាប្រចាំនូវរាល់កត្តាសំខាន់ៗទាំងឡាយដែលជាឫសគល់នៃសន្តិភាព ដែលក្នុងនោះមានការលើកកម្ពស់វប្បធម៌នៃភាពអហិង្សា និងការគោរពសិទ្ធិមនុស្ស ព្រមទាំងការលើកតម្កើងលទ្ធិប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ ហើយជាពិសេសបំផុត គឺការខិតខំកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស និងការលើកកម្ពស់ជីវភាពរបស់ប្រជាជន៉។

**ទី៣**, ក្នុងពិធីបិទមហាសន្និបាតពេញអង្គរបស់សមាគមនាទីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ **សម្តេចតេជោ ហ៊ុន សែន** បានមានប្រសាសន៍ដោយវាយតម្លៃខ្ពស់ចំពោះ ការចូលរួមចំណែកដ៏សក្តិសមរបស់សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ដែលតាំងពីថ្ងៃបង្កើតរបស់ខ្លួនជាមួយនឹងរណសិរ្ស ២ធ្នូ រហូតមកដល់ថ្ងៃនេះ ទោះបីបានផ្តាច់ខ្លួនពីស្ថាប័នមួយរបស់រាជរដ្ឋាភិបាលមកជាស្ថាប័នក្នុងសង្គមស៊ីវិលក៏ដោយក្តី តែសមាគមនិងសមាជិកាដ៏ច្រើនកុះកររបស់ខ្លួនតែងតែបានចូលរួមក្នុង

ចលនាការពារមាតុភូមិ កសាងសន្តិភាព និងការអភិវឌ្ឍ សង្គម អភិវឌ្ឍន៍វប្បធម៌ និងអភិវឌ្ឍន៍សេដ្ឋកិច្ច។

- គ្មាននារីកម្ពុជា ក៏គ្មានកម្ពុជាដែរ
- នារីកម្ពុជា គឺការលះបង់ដើម្បីជាតិនិងមាតុភូមិ
- នារីកម្ពុជា គឺជាក្តីសង្ឃឹមនៃការអភិវឌ្ឍកម្ពុជា

# កម្រងរូបភាព សកម្មភាពការងារ
# ចាប់ពីឆ្នាំ១៩៨១-១៩៩១



*សមមិត្តនារី ម៉ែន សំអន ចូលរួម ក្នុងពិធីពិព័រណ៍រូបភាព ស្តីពីការរីកចម្រើនរបស់យុវជន និងកុមារ*



*សមមិត្តនារី ម៉ែន សំអន ចូលរួម ក្នុងពិធីបញ្ចូលសមាជិកគណៈឃោសនាអប់រំមជ្ឈិម*



សមមិត្តនារី ម៉ែន សំអន ចូលរួមបោះឆ្នោត



គណៈកម្មាធិការមជ្ឈិមរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ធ្វើការប្រជុំ
ជ្រើសរើសបេក្ខជនឈរឈ្មោះរបស់សភា លើកទី ២
ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៨១




ពិធីសន្និបាតបូកសរុប ៥ឆ្នាំ ការងារបំផុសចលនាមហាជន អនុវត្ត ចលនា បដិវត្តទាំង ៣ កសាងមូលដ្ឋានរឹងមាំ ១៩៧៩-១៩៨៣



សមមិត្តនារី ម៉ែន សំអន អញ្ជើញសួរសុខទុក្ខយុទ្ធជនពិការនៅស្រុក កៀនស្វាយ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៨៤




*សមមិត្តនារី ម៉ែន សំអន អញ្ជើញចូលរួមក្នុង សន្និបាតប្រលងប្រណាំង ៥ល្អ របស់នារីទូទាំងប្រទេសលើកទី ១ ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៨៥ ក្រោមអធិបតីភាព សមមិត្ត ហ៊ុន សែន*



*សមមិត្តនារី ម៉ែន សំអន អញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋ*



សមមិត្តនារី ម៉ែន សំអន អញ្ជើញចូលរួមក្នុង ពិធីអបអរសាទរខួប
អនុស្សាវរីយ៍លើកទី ៧ (៧ មករា១៩៨៦) ក្រោមអធិបតីភាព
សមមិត្ត ហេង សំរិន



សមមិត្តនារី ម៉ែន សំអន អញ្ជើញជួបសំណេះសំណាល ជាមួយកម្មាភិបាល
ស្រុកសំបូរ ខេត្តក្រចេះ  ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៨៦



សមមិត្តនារី ម៉ែន សំអន ជួបសំណេះសំណាល និងសាកសួរសុខទុក្ខ
សិស្សមធ្យមសិក្សាទុតិយភូមិ នៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះ



សមមិត្តនារី ម៉ែន សំអន ជួបសន្ទនាជាមួយឃុំគំរូទូទាំងប្រទេសលើកទី១
ឆ្នាំ១៩៨៨ ក្រោមអធិបតីភាព សមមិត្ត ហេង សំរិន ប្រធានក្រុមប្រឹក្សារដ្ឋ



សមមិត្តនារី ម៉ែន សំអន អនុញ្ញាតឲ្យ សមមិត្ត ហ្សវហ្សហូកូមី យាលការ
ឯកអគ្គរដ្ឋទូតប៉ូឡូញប្រចាំនៅកម្ពុជា ចូលជួបសម្តែងការគួរសម



សមមិត្តនារី ម៉ែន សំអន ចុះអនុវត្តការងារតាមសេចក្តីសម្រេចរបស់
គណៈកម្មការមជ្ឈិម ស្តីពីការកសាង វណ្ណៈកម្មករនៅកម្ពុជា ឲ្យក្លាយទៅ
ជាវណ្ណៈឈានមុខពិតប្រាកដ នៅរោងចក្រតម្បាញ ២



សមមិត្តនារី ម៉ែន សំអន ថ្លែងសុន្ទរកថា ក្នុងមហាសន្និបាតសមាគម
អ្នកកាសែតកម្ពុជាលើកទី ១



សមមិត្តនារី ម៉ែន សំអន អញ្ជើញចូលរួមក្នុង
ពិធីមហាសន្និបាតតំណាងសហជីពទូទាំងប្រទេសលើកទី២
ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៨៨ ក្រោមអធិបតីភាព
សមមិត្ត ហេង សំរិន ប្រធានក្រុមប្រឹក្សារដ្ឋ



សមមិត្តនារី ម៉ែន សំអន អញ្ជើញចូលរួមក្នុងមហាសន្និបាតបក្សភាគខេត្ត លើកទី ១

ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ១៩៨៨



សមមិត្តនារី ម៉ែន សំអន អញ្ជើញចូលរួមក្នុងមហាសន្និបាតបក្សភាគខេត្ត លើកទី ១

ខេត្តសៀមរាប ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ១៩៨៨



សមមិត្តនារី ម៉ែន សំអន អញ្ជើញចូលរួមក្នុងមហាសន្និបាតបក្សភាគខេត្ត លើកទី ១

ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ១៩៨៨



សមមិត្តនារី ម៉ែន សំអន ចូលរួមក្នុងពិធីទិវាចងកំហឹង ២០ ឧសភា

ក្រោមអធិបតីភាព សមមិត្ត ហេង សំរិន ប្រធានក្រុមប្រឹក្សារដ្ឋ

ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨៨



សមមិត្តនារី ម៉ែន សំអន អញ្ជើញទទួលដំណើរនិវត្តមកដល់របស់
សមមិត្ត ហ៊ុន សែន សមាជិកការិយាល័យនយោបាយប្រធានក្រុមប្រឹក្សា
រដ្ឋមន្ត្រីត្រលប់មកពីប្រជុំនៅហ្សាកាតា ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៨៩



សមមិត្តនារី ម៉ែន សំអន ប្រធានគណៈចាត់តាំងមជ្ឈិម អញ្ជើញចុះសួរ
សុខទុក្ខប្រជាជន កម្មាភិបាល បុគ្គលិក កម្មករ  នៅខេត្តកំពង់ចាម
ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៩



សមមិត្តនារី ម៉ែន សំអន អញ្ជើញថ្វាយបង្គំព្រះសង្ឃ នៅវត្តពោធិរ៉ាម
ស្រុកចំការលើ ខេត្តកំពង់ចាម ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៩



សមមិត្តនារី ម៉ែន សំអន អញ្ជើញចុះសួរសុខទុក្ខកម្មករ កម្មការិនី
នៅចំការកៅស៊ូ ខេត្តកំពង់ចាម ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៩




ពិធីសន្និបាតមជ្ឈិមបក្សលើកទី ១០ នីតិកាលទី ១ ក្រោមអធិបតីភាព
របស់ សមមិត្ត ហេង សំរិន ប្រធានក្រុមប្រឹក្សារដ្ឋ
ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៩០



ពិធីសន្និបាតមជ្ឈិមបក្សលើកទី ១០ នីតិកាលទី ១ ក្រោមអធិបតីភាព
របស់ សមមិត្ត ហេង សំរិន ប្រធានក្រុមប្រឹក្សារដ្ឋ
ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៩០



សមមិត្តនារី ម៉ែន សំអន ប្រធានគណៈចាត់តាំងមជ្ឈិម
ថ្លែងសុន្ទរកថា ក្នុងពិធីសន្និបាតបូកសរុបការងារទូទាំងប្រទេស



សមមិត្តនារី ម៉ែន សំអន អញ្ជើញរាប់បាត្រ នៅខេត្តតាកែវ



សមមិត្តនារី ម៉ែន សំអន អញ្ជើញដាំដើមឈើនៅមុខសក្យមុនីចេតិយ៍



ពិធីបើកសម័យប្រជុំសភា លើកទី ២០ នីតិកាលទី ១ ក្រោមអធិបតីភាព
របស់ សមមិត្ត ជា ស៊ីម ប្រធានរដ្ឋសភា ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩១



សមមិត្តនារី ម៉ែន សំអន អញ្ជើញសំណេះសំណាលជាមួយក្រុមតន្ត្រី
ជាជនពិការនៅស្រុកកៀនស្វាយ



សមមិត្តនារី ម៉ែន សំអន អញ្ជើញសំណេះសំណាលជាមួយកងទ័ពជើង
ទឹកការពារព្រំដែនសមុទ្រតំបន់៤ ខេត្តព្រះសីហនុ

## ប្រវត្តិការងារពីឆ្នាំ ១៩៩៣ ដល់បច្ចុប្បន្ន

- ១៩៩៣ ដល់បច្ចុប្បន្ន តំណាងរាស្ត្រមណ្ឌលស្វាយរៀង
- ១៩៩៧ ទទួលបាននូវស័ក្តិជាឧត្តមសេនីយ៍ទោ
- ១៩៩៩ ប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍
- ១៩៩៩-២០០៣ ប្រធានគណៈកម្មការសុខាភិបាលសង្គមកិច្ច និងកិច្ចការនារីនៃរដ្ឋសភា
- ២០០០ ប្រធានសមាគមសមាជិកសភាពកម្ពុជាដើម្បីប្រជារាស្ត្រ និងការអភិវឌ្ឍ
- ២០០៤ តែងតាំងជា ទេសរដ្ឋមន្ត្រី
- ២០០៥ ទទួលបាន្តូរស័កជាឧត្តមសេនីយ៍ឯក
- ២០០៦ តែងតាំងជាប្រធានសមាគមមិត្តភាពកម្ពុជា-វៀតណាម

- ២០០៨ ទេសរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- ២០០៨ តែងតាំងជាឧបនាយករដ្ឋមន្ត្រី
- ២០០៨ ទទួលឋានន្តរស័ក្តិ នាយឧត្តមសេនីយ៍ (ផ្កាយមាស ៤) នៃកងយោធពលខេមរភូមិន្ទ
- ២០១៥ ប្រធានគណៈចលនាមហាជន
- ២០២១ តែងតាំងជាអនុប្រធានគណបក្ស
- ២០២៣ ត្រូវបានព្រះមហាក្សត្រត្រាស់បង្គាប់ផ្តល់គោរមងារជា «សម្តេចកិត្តិសង្គហបណ្ឌិត»
- ២០២៣ ត្រូវបានមហាសន្និបាតវិសាមញ្ញរបស់រណសិរ្ស បោះឆ្នោតជ្រើសរើសជាប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា
- ២០២៣-បច្ចុប្បន្ន៖ ត្រូវបានតែងតាំងជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

- ២០១៥-២០២៥ អនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
- ២០២៥ ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
- ២០២៥ ទទួលបាននូវសក្តិ នាយឧត្តមសេនីយ៍ផុតលេខ (ផ្កាយមាស ៥) នៃកងយោធពលខេមរភូមិន្ទ

មតិផ្តាំផ្ញើមុនបញ្ចប់ការធ្វើបាឋកថា

(លើមូលដ្ឋាននៃសាររបស់សម្តេចតេជោ)

តាមរយៈ សារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា ក្នុងទិវារំឭកខួបលើកទី៧៥ នៃថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ក្នុងនាមប្រមុខបក្សសម្តេចបានបញ្ជាក់ជំហរ និងការប្តេជ្ញាចិត្តរបស់គណបក្សប្រជាជនកម្ពុជាចំនួន ៥ចំណុចជូនជនរួមជាតិក្នុងឱកាសខួប៧៥ឆ្នាំនៃការបង្កើតគណបក្ស ដូចតទៅ៖

១- គណបក្សប្រជាជនកម្ពុជា ប្តូរផ្តាច់ការពារអធិបតេយ្យ បូរណភាពទឹកដី និងសន្តិភាពឲ្យស្ថិតស្ថេរគង់វង្ស បន្ត

ខិតខំជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឲ្យរីកចម្រើនខ្លាំងក្លា ពង្រឹងយុត្តិធម៌ សមធម៌ និងសមភាពក្នុងសង្គម និង លើកស្ទួយជីវភាពប្រជាជនឲ្យបានកាន់តែប្រសើរឡើង។ គណបក្សប្រកាន់ខ្ជាប់គោលនយោបាយការបរទេសរបស់ខ្លួន ក្នុងការកសាងទំនាក់ទំនងល្អជាមួយប្រទេសជិតខាងទាំងអស់ដោយឈរលើមូលដ្ឋានគោរពឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីផងគ្នា ស្មើភាព និង មានផលប្រយោជន៍ទៅវិញទៅមក ដើម្បីជានានូវសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការស្ថិតស្ថេរយូរអង្វែង រវាងប្រជាជាតិជិតខាងភូមិផងរបងជាមួយ។

២- គណបក្សប្រជាជនកម្ពុជា គាំទ្រពេញទំហឹងការប្រឹងប្រែង ជំសកម្មរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាព្រំដែន ទាំងព្រំដែនគោក និងព្រំដែនសមុទ្រជាមួយប្រទេសថៃដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ និង កិច្ចព្រមព្រៀងដែលមានស្រាប់ ធម្មនុញ្ញអាស៊ាន និង សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍។ កម្ពុជាមិនទទួលស្គាល់ខ្សែព្រំដែនណាមួយដែលបង្កើតឡើងតាមរយៈការប្រើប្រាស់កម្លាំង ការកាន់កាប់ ឬការទាមទារទឹកដីជាឯកតោភាគីនោះឡើយ ហើយកម្ពុជាក៏

មិនទទួលយកការប៉ុនប៉ងណាមួយដើម្បីផ្លាស់ប្តូរស្ថានភាពនៃទឹកដីកម្ពុជា តាមរយៈការបង្កើតនូវអ្វីដែលបានកើតឡើងរួចហើយនៅលើទីកន្លែងនោះ។ ក្នុងន័យនេះ យើងអំពាវនាវឲ្យមានការអនុវត្តយ៉ាងពេញលេញនូវសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣ របស់គណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។ ជាមួយនេះ គណបក្សគាំទ្រការសម្រេចប្រើប្រាស់យន្តការនៃការផ្សះផ្សាដោយបង្ខំ ដែលស្ថិតក្រោមអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីនីតិសមុទ្រ (UNCLOS) ដើម្បីស្វែងរកដំណោះស្រាយដោយសន្តិវិធីផ្អែកលើមូលដ្ឋានច្បាប់ ចំពោះតំបន់ទាមទារដែនសមុទ្រត្រួតស៊ីគ្នារវាងកម្ពុជា និងថៃ។

៣- គណបក្សប្រជាជនកម្ពុជា គាំទ្រការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា ដើម្បីកសាងសង្គមមួយប្រកបដោយធនធានមនុស្សដែលមានវិន័យ សីលធម៌ សមត្ថភាព មានមនសិការស្នេហាជាតិ មានភាពអង់អាច មានឆន្ទៈមោះមុត និងត្រៀមខ្លួនរួចជាស្រេចគ្រប់ពេលវេលាដើម្បីបុព្វហេតុការពារជាតិ មាតុភូមិ។

៤- ខ្ញុំសូមអំពាវនាវដល់ប្រជាជនកម្ពុជាគ្រប់រូប ខិតខំលើកកម្ពស់ភាពឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន របស់ជាតិយើង ឆ្លើយតបនឹងសំណូមពរនៃសភាពការណ៍ជាតិ និងការវិវត្តយ៉ាងស្មុគស្មាញនៃសភាពការណ៍អន្តរជាតិ ដើម្បីការពារមាតុភូមិ និងសម្រេចទិសដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា។ ក្នុងស្មារតីនេះ សូមបងប្អូនជនរួមជាតិបន្តរួមសាមគ្គីជាធ្លុងមួយជុំវិញរាជរដ្ឋាភិបាល និងគាំទ្រយ៉ាងរឹងមាំដល់វីរកងកម្លាំងប្រដាប់អាវុធកម្ពុជា ដែលកំពុងឈរជើងការពារទឹកដីមាតុភូមិជាទីស្នេហាស្មើជីវិតរបស់យើង។ ក្នុងស្មារតីនេះដែរ យើងត្រូវបន្តខិតខំពង្រីកផលិតកម្មក្នុងស្រុក និងលើកស្ទួយការប្រើប្រាស់ផលិតផលជាតិឲ្យបានគ្រប់ៗគ្នា។

៥- ខ្ញុំសូមអំពាវនាវដល់គណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ មន្ត្រី សមាជិក សមាជិកាគណបក្សប្រជាជនកម្ពុជាទាំងមូល យកចិត្តទុកដាក់ពង្រឹងសាមគ្គីភាពឯកភាពផ្ទៃក្នុងឲ្យកាន់តែរឹងមាំ ប្រកាន់ខ្ជាប់ប្រពៃណីដ៏ថ្លៃថ្លារបស់គណបក្ស ខិតខំបម្រើប្រជាជនឲ្យអស់ពីចិត្តពីថ្លើមនិងចូលរួមសកម្មក្នុងការអនុវត្តកម្មវិធីនយោបាយរបស់គណបក្សឲ្យបានសម្រេចជោគជ័យ។ *សូមអរគុណ!*